**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**គណៈកម្មាធិការជាតិ សុខភាព**
**និងសុវត្ថិភាពការងារ**
លេខ.....០០៤៧/១៨...គ.ជ.ស.ក

ថ្ងៃ ពុធ ៦កើត ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១៨

# សេចក្ដីសម្រេច
# ស្ដីពី
# ការបង្កើតក្រុមការងារសិក្សាស្រាវជ្រាវ ផ្ដល់យោបល់ ទប់ស្កាត់ករណីដួលសន្លប់របស់កម្មករនិយោជិតនៅតាមសហគ្រាស គ្រឹះស្ថាន

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
## និងជាប្រធានគណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២៣៧ អនក្រ.បក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ

-យោងលិខិតបង្គាប់ការលេខ ០២២សខល ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងសុខាភិបាល

- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារសិក្សាស្រាវជ្រាវ ផ្តល់យោបល់ ទប់ស្កាត់ករណីដួលសន្លប់របស់កម្មករនិយោជិត នៅតាមសហគ្រាស គ្រឹះស្ថានដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២-ឯ.ឧ សាស្ត្រាចារ្យ | **អេង ហួត** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៣-ឯកឧត្តមវេជ្ជ. | **ហ៊ុយ ហានសុខ** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤-ឯកឧត្តម | **ផេង សុខាំ** | អនុរដ្ឋលេខាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៥-ល.ជ សាស្ត្រាចារ្យ | **អ៊ុំ សាម៉ុល** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិកា |
| ៦-ឯកឧត្តម | **ស៊ឹម យ៉ារ៉ែន** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៧-ឯកឧត្តម | **កៅ ធារ៉ូ** | អនុរដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៨-ឯកឧត្តម | **កៅ ផល** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | សមាជិក |
| ៩-ឯកឧត្តម | **ជា វុទ្ធី** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១០-ឯ.ឧ សាស្ត្រាចារ្យ | **ឈួយ ម៉េង** | ទីប្រឹក្សាក្រសួងសុខាភិបាល | សមាជិក |
| ១១-ឯកឧត្តម | **ហេង សួរ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១២-ឯកឧត្តម | **សេង សក្ដា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ | សមាជិក |
| ១៣-ឯកឧត្តម | **ឡៅ ហ៊ីម** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានTVET | សមាជិក |
| ១៤-ឯកឧត្តម | **អ៊ុក សមវិទ្យា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុក នាយកបេឡាជាតិរបបសន្តិសុខសង្គម | សមាជិក |
| ១៥-លោកជំទាវវេជ្ជ. | **ឱ វណ្ណឌីន** | អគ្គនាយកបច្ចេកទេសសុខាភិបាល | សមាជិកា |
| ១៦-ឯ.ឧសាស្ត្រាចារ្យ | **សាធុន វឌ្ឍនៈ** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល | សមាជិក |
| ១៧-លោកជំទាវ | **ជា សុខនី** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិកា |

| | | | |
|---|---|---|---|
| | | នៃអគ្គនាយកដ្ឋានការងារ | សមាជិកា |
| ១៩-ល.សាស្ត្រាចារ្យរង | **ឈា ឆវណ្ណា** | នាយកវិទ្យាស្ថានជាតិសុខភាពសាធារណៈ | សមាជិក |
| ២០-លោកវេជ្ជ. | **ឈិត សុផល** | ប្រធាននាយកដ្ឋានសុខភាពផ្លូវចិត្តនិងការ<br>បំពានគ្រឿងញៀន | សមាជិក |
| ២១-លោក | **សារិ ផល្លា** | ប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម<br>នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ២២-លោក | **ខេន លូ** | អគ្គលេខាធិការនៃសមាគមកាត់ដេរនៅកម្ពុជា | សមាជិក |
| ២៣-លោក | **គីម ពេជ្ជដា** | ប្រធានផ្នែកការងារនិងច្បាប់នៃសមាគមកាត់ដេរនៅកម្ពុជា | សមាជិក |
| ២៤-លោក | **តោ ដារ៉ារិទ្ធ** | មន្ត្រីការងារ នៃសមាគមកាត់ដេរនៅកម្ពុជា | សមាជិក |
| ២៥-លោក | **ជួន មុំថុល** | ប្រធានសហភាពសហព័ន្ធសហជីពជាតិកម្ពុជា | សមាជិក |
| ២៦-លោកស្រី | **ទេព គីមវណ្ណារី** | អនុប្រធានសហភាពសហព័ន្ធសហជីពជាតិកម្ពុជា | សមាជិកា |
| ២៧-លោក | **ណៃ សុខវាសនា** | អគ្គហិរញ្ញិកសហភាពសហព័ន្ធសហជីពជាតិកម្ពុជា | សមាជិក |
| ២៨-លោកស្រី | **ផន សុផារី** | តំណាងអង្គការសុខភាពពិភពលោក | សមាជិកា |
| ២៩-លោក | **ទុន សុភ័ណ** | អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិនៃអង្គការ ILO | សមាជិក |
| ៣០-លោកស្រី | Esther Germans | ប្រធានគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា<br>នៃអង្គការ ILO | សមាជិកា |

**ប្រការ ២.-**

ក្រុមការងារនេះមានភារកិច្ចៈ

- ពិនិត្យ និងផ្តល់យោបល់លើគោលនយោបាយ និងដំណោះស្រាយដើម្បីទប់ស្កាត់ការដួលសន្លប់ និងគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ
- គ្រប់គ្រង និងសម្របសម្រួលការសិក្សាស្រាវជ្រាវដើម្បីរកវិធីសាស្ត្របង្ការការដួលសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ
- រៀបចំបទប្បញ្ញត្តិចាំបាច់ដើម្បីបង្ការ និងទប់ស្កាត់ការដួលសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ
- ផ្តល់វិធានការជាបន្ទាន់ដើម្បីទប់ស្កាត់ករណីដួលសន្លប់ និងគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ
- ពិនិត្យ និងផ្តល់យោបល់លើផែនការសកម្មភាពពាក់ព័ន្ធនឹងការទប់ស្កាត់ការដួលសន្លប់និងបង្ការគ្រោះថ្នាក់ការងារ
- ពិនិត្យ និងផ្តល់យោបល់លើកម្មវិធីអប់រំ/ផ្សព្វផ្សាយពីវិធានការទប់ស្កាត់ការដួលសន្លប់ និងការបង្ការគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ
- សហការ និងសម្របសម្រួលជាមួយបណ្តាប្រទេសជាមិត្ត ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិ វិស័យឯកជន និងសង្គមស៊ីវិល ដើម្បីគៀរគរធនធាន បច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់គាំទ្រដល់សកម្មភាពលើកកម្ពស់ការទប់ស្កាត់ការដួលសន្លប់ និងគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ
- ធ្វើរបាយការណ៍ការងារ សេចក្តីព្រាងនៃការសន្និដ្ឋានចុងក្រោយ និងសេចក្តីសម្រេចនានាដាក់ជូនរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានគណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារប្រគល់ជូន។ HS

**ប្រការ ៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នាយកបេឡាជាតិរបបសន្តិសុខសង្គម និងប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ ព្រមទាំងសាមីខ្លួនមានភារកិច្ចអនុវត្តតាមសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ១៤

**រដ្ឋមន្ត្រី និងជាប្រធាន**
**គណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ**

**អ៊ិត សំហេង**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់អង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រប់សមាគមនិយោជក
- គ្រប់សហព័ន្ធសហជីព
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ